**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ៨៦.អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការកែសម្រួលមាត្រា២នៃអនុក្រឹត្យលេខ១៦៨ អនក្រ.បក ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៥៨ អនក្រ.បកចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ១៦៨ អនក្រ.បក ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍
- យោងតាមសំណើរបស់គណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍

## សម្រេច

**មាត្រាមួយ .-**

មាត្រា២នៃអនុក្រឹត្យលេខ១៦៨ អនក្រ.បក ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិអភិវឌ្ឍន៍ទេសចរណ៍ ត្រូវបានធ្វើការកែសម្រួល ដូចតទៅៈ

**មាត្រា២ .- ថ្មី**

សមាសភាពនៃ **គ.ជ.អ.ទ.**មានដូចខាងក្រោម៖

| | | |
|---|---|---|
| ១- | ឧបនាយករដ្ឋមន្ត្រី១រូប | ប្រធាន |
| ២- | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- | រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន | អនុប្រធាន |
| ៤- | រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | អនុប្រធាន |
| ៥- | រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៦- | រដ្ឋមន្ត្រីក្រសួងបរិស្ថាន | អនុប្រធាន |
| ៧- | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | សមាជិក |
| ៨- | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៩- | រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល | សមាជិក |
| ១០- | រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១១- | រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១២- | រដ្ឋមន្ត្រីក្រសួងសុខាភិបាល | សមាជិក |
| ១៣- | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៤- | រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ១៥- | រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម | សមាជិក |
| ១៦- | រដ្ឋមន្ត្រីក្រសួងកិច្ចការនារី | សមាជិក |
| ១៧- | រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ១៨- | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១៩- | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ១រូប | សមាជិក |
| ២០- | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ១រូប | សមាជិក |
| ២១- | រដ្ឋលេខាធិការក្រសួងការពារជាតិ ១រូប | សមាជិក |
| ២២- | រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ១រូប | សមាជិក |
| ២៣- | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប | សមាជិក |
| ២៤- | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ១រូប | សមាជិក |
| ២៥- | រដ្ឋលេខាធិការក្រសួងផែនការ ១រូប | សមាជិក |
| ២៦- | អគ្គស្នងការនគរបាលជាតិ | សមាជិក |
| ២៧- | មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ២៨- | អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | សមាជិក |
| ២៩- | អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៣០- | អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ៣១- | តំណាងក្រសួងទេសចរណ៍ ៨រូប | សមាជិក |
| ៣២- | ប្រធានគណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍រាជធានីខេត្ត | សមាជិក។ |

សមាសភាពជាក់ស្តែងនៃ**គ.ជ.អ.ទ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រាពីរ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រាបី .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៧រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

**ថោង ខុន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបី
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ